**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**
ក្រសួងមហាផ្ទៃ- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

**លេខ** :.... ០០១ ... ... ... សរ.មផ - បទ

# សារាចរអន្តរក្រសួង
# ស្តីពី
# ការគ្រប់គ្រងការធ្វើអាជីវកម្ម និង ការប្រើប្រាស់សេវាកម្មទូរគមនាគមន៍

ការវិវឌ្ឍន៍រីកចម្រើននៃបច្ចេកវិទ្យាក្នុងវិស័យទូរគមនាគមន៍ ត្រូវបាន និងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់បម្រើសកម្មភាពសេដ្ឋកិច្ច សង្គម ការទូត សំដៅលើកកម្ពស់ចំណេះដឹង និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចថែរក្សាសន្តិសុខជាតិ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈឱ្យកាន់តែល្អប្រសើរឡើង។ ប្រការនេះបានជំរុញការប្រើប្រាស់ទូរស័ព្ទ-ទូរសារ និង អ៊ិនធឺណែតឱ្យមានសន្ទុះកើនឡើងគួរកត់សម្គាល់។

តាមបទពិសោធន៍ ក្នុងការស្រាវជ្រាវបង្ក្រាបបទល្មើសនានាកន្លងមក បានបង្ហាញឱ្យឃើញថា ៖ ពួកឧក្រិដ្ឋជន និងជនទុច្ចរិត តែងតែប្រើប្រាស់សេវាកម្មទូរគមនាគមន៍រួមមាន៖ ទូរស័ព្ទចល័ត ទូរស័ព្ទអចល័ត VoIP និងអ៊ិនធឺណែត ជាមធ្យោបាយធ្វើសកម្មភាពភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន អំពើឆក់ប្លន់ ការចាប់មនុស្សជំរិតទារប្រាក់ អំពើឃាតកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស បទល្មើសសេដ្ឋកិច្ច ការលួចដំឡើង និងធ្វើអាជីវកម្មសេវាកម្មទូរគមនាគមន៍ខុសច្បាប់តាមគ្រប់រូបភាព ការបញ្ជូនផ្សព្វផ្សាយរូបភាពអាសអាភាស និងអំពើអនាចារផ្សេងៗទៀត ដែលធ្វើឱ្យប៉ះពាល់ទំនៀមទម្លាប់ប្រពៃណីរបស់ជាតិ និងសីលធម៌ស្អាតស្អំរបស់សង្គម។

ក្នុងមូលហេតុខាងលើនេះ ដើម្បីលើកកម្ពស់ការការពារសន្តិសុខជាតិ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមឱ្យកាន់តែល្អប្រសើរ ស័ក្តិសមជានីតិរដ្ឋ ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានសម្រេចណែនាំប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់ ព្រមទាំងអ្នកជួលជាវសេវាទូរគមនាគមន៍ដូចខាងក្រោម ៖

១) អំពីសំណុំបែបបទដែលត្រូវបំពេញ

ប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់បំផុត ក្នុងការតម្រូវឱ្យអ្នកជួលជាវសេវាទូរគមនាគមន៍បំពេញសំណុំបែបបទដូចខាងក្រោម៖

ក) ជនជាតិខ្មែរ

១) ប្រជាពលរដ្ឋទូទៅ ត្រូវប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលកំពុងមានសុពលភាព។

២)មន្ត្រីរាជការគ្រប់ប្រភេទ ត្រូវប្រើប្រាស់លិខិតសម្គាល់ខ្លួនចេញដោយក្រសួង ស្ថាប័ន អង្គភាពសាមី។

៣) ចំពោះព្រះសង្ឃ ត្រូវប្រើប្រាស់សង្ឃដីកា។

៤) ដោយឡែក ចំពោះអនីតិជនចាំបាច់ត្រូវឲ្យឪពុកម្តាយ ឬអាណាព្យាបាល ជាអ្នកជួលជាវឲ្យប្រើប្រាស់។

ឯកសារដទៃក្រៅពីការកំណត់ខាងលើ ពុំមានតម្លៃគតិយុត្តិសម្រាប់ប្រើប្រាស់ជួលជាវសេវាទូរគមនាគមន៍ទេ។

ខ) ជនបរទេស

ជនបរទេស ជារូបវន្តបុគ្គលទាំងពីរភេទ ដែលមានបំណងជួលជាវសេវាទូរគមនាគមន៍ ត្រូវប្រើប្រាស់លិខិតឆ្លងដែន ភ្ជាប់ដោយទិដ្ឋាការស្នាក់នៅមានសុពលភាព។

គ) ស្ថានទូត អង្គការ សមាគម អង្គភាព ក្រុមហ៊ុន

បណ្ដាស្ថានទូត អង្គការ សមាគម អង្គភាព ក្រុមហ៊ុន ដែលមានគម្រោងជួលជាវសេវាទូរគមនាគមន៍សម្រាប់ប្រើប្រាស់ជាលក្ខណៈរួម ត្រូវបំពេញសំណុំលិខិតផ្ទេរការ និងកំណត់អំពីការទទួលខុសត្រូវរបស់បុគ្គលឱ្យបានច្បាស់លាស់។

ការប្រើប្រាស់ឯកសារដូចមានចែងក្នុងចំណុចទី១.ក ចំណុចទី១.ខ និងចំណុចទី១.គ សម្រាប់ជាវលេខទូរស័ព្ទ ឬជួលជាវសេវាទូរគមនាគមន៍ ត្រូវតែមានឯកសារផ្ទាល់ខ្លួនគ្រប់គ្រាន់ដោយខានពុំបាន សម្រាប់បំពេញបែបបទតាមការកំណត់ នៃសារាចរអន្តរក្រសួងនេះ។ ការប្រើប្រាស់ឯកសាររបស់អ្នកដទៃ ត្រូវហាមឃាត់ជាដាច់ខាត។

២) សមត្ថកិច្ច នគរបាល សមត្ថកិច្ចក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងប្រតិបត្តិករទូរគមនាគមន៍ ត្រូវរួមគ្នាត្រួតពិនិត្យឡើងវិញ ចំពោះសំណុំបែបបទចាស់ ដែលមិនត្រឹមត្រូវ ឬពុំច្បាស់លាស់ ដូចជា៖ ខ្វះឯកសារអត្តសញ្ញាណប័ណ្ណ ឬអត្តសញ្ញាណប័ណ្ណក្លែងក្លាយ លិខិតសម្គាល់ខ្លួនក្លែងក្លាយ ឬសង្ឃដីកាក្លែងក្លាយ។ បន្ទាប់មកត្រូវជូនដំណឹងដល់សាមីជន ដែលកំពុងប្រើប្រាស់លេខទូរស័ព្ទ ឬភ្ជាប់បណ្ដាញរួចហើយ មកបំពេញសំណុំបែបបទផ្ទាល់ខ្លួន ឱ្យបានត្រឹមត្រូវដូចមានចែងក្នុងចំណុចទី១ នៃសារាចរអន្តរក្រសួងនេះ ក្នុងរយៈពេល ០១ខែ។ ករណីហួស ពេលបានកំណត់ ត្រូវផ្អាកដំណើរការជាបណ្ដោះអាសន្ន។

៣)ប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់ មានកាតព្វកិច្ចចុះបញ្ជីអាជីវកម្មនៅតាមមូលដ្ឋាន។ ទន្ទឹមនឹងនេះនៅគ្រប់ទីតាំងបម្រើសេវាជួលទូរស័ព្ទ និងអ៊ិនធឺណែតសាធារណៈ ត្រូវបំពាក់កាម៉ារ៉ាថត និងរក្សាទុកទិន្នន័យរូបភាពអ្នកប្រើប្រាស់រយៈពេលយ៉ាងតិចបំផុត០៣ខែ។

ចំពោះអ្នកធ្វើអាជីវកម្មទូរស័ព្ទបម្រើតាមដងផ្លូវសាធារណៈ ត្រូវធ្វើកំណត់ត្រាអត្តសញ្ញាណប័ណ្ណរបស់អ្នកដែលបានជួលប្រើប្រាស់។

៤)ប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់មានកាតព្វកិច្ចទទួលខុសត្រូវគ្រប់គ្រងអត្តសញ្ញាណប័ណ្ណ ឬលិខិតសម្គាល់ខ្លួន ឬសង្ឃដីកា ថតចម្លងរបស់អ្នកជួលជាវ និងធានាបច្ចេកទេសកត់ត្រាទិន្នន័យប្រើប្រាស់ក្នុងរយៈពេល០៦ខែ។

៥)ប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់មានកាតព្វកិច្ចផ្តល់សំណុំឯកសារចាំបាច់ រួមមាន៖ អត្តសញ្ញាណប័ណ្ណនៃអ្នកប្រើប្រាស់ ទិន្នន័យនៃការប្រើប្រាស់តាមការស្នើរបស់សមត្ថកិច្ច សម្រាប់បម្រើការស្រាវជ្រាវបទល្មើសទាំងឡាយដែលទាក់ទងនឹងបញ្ហាសន្តិសុខជាតិ សុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម។

ប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់ ដែលពាក់ព័ន្ធ ត្រូវផ្តល់ឯកសារដែលសមត្ថកិច្ចបានស្នើសុំឱ្យគ្រប់គ្រាន់ និងឆាប់រហ័សបំផុត ទោះបីថ្ងៃឈប់សម្រាក ថ្ងៃបុណ្យជាតិ អន្តរជាតិ ក៏ត្រូវមានបុគ្គលិកប្រចាំការអចិន្ត្រៃយ៍សម្រាប់បំពេញកាតព្វកិច្ចនេះដែរ។

៦)ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងចាត់មន្ត្រីចុះប្រចាំការជាមួយប្រតិបត្តិករទូរគមនាគមន៍ទាំងអស់។ ទន្ទឹមនឹងនេះ ត្រូវចាត់តាំងមន្ត្រីសហការជាមួយ សាខាលក់ និងចែកចាយបន្តទាំងអស់ ដែលពាក់ព័ន្ធដើម្បីស្រាវជ្រាវឯកសារទិន្នន័យឱ្យទាន់ពេលវេលា។

៧)មានតែមន្ត្រីដែលទទួលការប្រគល់ភារកិច្ចពីប្រមុខរាជរដ្ឋាភិបាល ឬ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងអគ្គស្នងការនគរបាលជាតិប៉ុណ្ណោះ ទើបមានសិទ្ធិស្នើប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់ ដែលពាក់ព័ន្ធឱ្យផ្តល់ឯកសាររបស់អ្នកជួលជាវសេវាទូរគមនាគមន៍។ ក្រៅពីនេះ ទោះបីកម្លាំងសមត្ថកិច្ចណា ឬសាមីប្រតិបត្តិករទូរគមនាគមន៍ សាមីសាខាលក់ និងចែកចាយបន្តទាំងអស់ ក៏ពុំមានសិទ្ធិត្រួតពិនិត្យ ឬបញ្ចេញឯកសាររបស់អ្នកជួលជាវសេវាទូរគមនាគមន៍ឡើយ។

សមត្ថកិច្ច ឬប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តណាមួយបានប្រព្រឹត្តផ្ទុយពីការកំណត់ខាងលើ នឹងត្រូវទទួលទណ្ឌកម្មតាមរូបភាពដាក់វិន័យ ឬផ្តន្ទាទោសតាមច្បាប់ជាធរមាន។

៨)ចំពោះអ្នកជួលជាវសេវាទូរគមនាគមន៍ ត្រូវយកចិត្តទុកដាក់អនុវត្តតាមការណែនាំដូចខាងក្រោម៖

ក) អ្នកជួលជាវសេវាទូរគមនាគមន៍ ដែលផ្លាស់ប្តូរលំនៅ ឬបាត់លេខទូរស័ព្ទត្រូវផ្តល់ព័ត៌មានជូនប្រតិបត្តិករទូរគមនាគមន៍ ឬ សាខាលក់ និងចែកចាយបន្តណាមួយឱ្យបានឆាប់រហ័សបំផុត។

ខ) អ្នកដែលកំពុងប្រើសេវាទូរគមនាគមន៍គ្រប់ប្រភេទ ហើយមានបំណងផ្តល់ទៅឱ្យអ្នកដទៃ ត្រូវធ្វើលិខិតបញ្ជាក់ផ្ទេរ។ រីឯអ្នកទទួលយកសេវាទៅប្រើប្រាស់បន្តត្រូវយកលិខិតបញ្ជាក់នោះ ដោយភ្ជាប់បន្ថែមជាមួយនូវឯកសារផ្ទាល់ខ្លួន (ដូចមានចែងក្នុងចំណុចទី ១ខាងលើ ) ទៅបំពេញទម្រង់បែបបទថ្មីជូនប្រតិបត្តិករទូរគមនាគមន៍ ឬ សាខាលក់ និងចែកចាយបន្តណាមួយតាមជាក់ស្តែង។

៩)ដោយឡែក រាល់ការធ្វើអាជីវកម្មប្រព័ន្ធវលកអាកាសវិទ្យុទាក់ទង ត្រូវតែសុំច្បាប់អនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ចំពោះប្រេកង់នៃកម្លាំងសមត្ថកិច្ច ដែលបានកំណត់ឱ្យប្រើប្រាស់សម្រាប់បំពេញការងាររដ្ឋ សាមីស្ថាប័នជាអ្នកសម្រេចលើការប្រើប្រាស់ ដោយមិនអនុញ្ញាតឱ្យធ្វើអាជីវកម្ម។

អ្នកលួចប្រើប្រាស់ប្រព័ន្ធវលកអាកាសវិទ្យុទាក់ទង នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

១០)ក្រសួងមហាផ្ទៃ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សំណូមពរប្រតិបត្តិករទូរគមនាគមន៍ សាខាលក់ និងចែកចាយបន្តទាំងអស់ ព្រមទាំងអ្នកជួលជាវសេវាទូរគមនាគមន៍នឹងសហការអនុវត្តតាមស្មារតីសារាចរអន្តរក្រសួងនេះ ប្រកបដោយប្រសិទ្ធភាព ដើម្បីរួមចំណែកថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមពុំខាន។

ប្រសិនបើប្រតិបត្តិករទូរគមនាគមន៍ ឬ សាខាលក់ និងចែកចាយបន្តណាមួយបំពានមិនសហការអនុវត្តតាមសារាចរអន្តរក្រសួងនេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នឹងចាត់វិធានការដកហូតអាជ្ញាប័ណ្ណអាជីវកម្មតាមជាក់ស្តែង។

ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ ឬ សាខាលក់ និងចែកចាយបន្តណាមួយមិនព្រមសហការអនុវត្តតាមសារាចរអន្តរក្រសួងនេះ ហើយជាដើមហេតុបង្កឱ្យមានបទល្មើស ក្រសួងមហាផ្ទៃ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងសហការកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីចាត់ការតាមច្បាប់ធរមាន។

អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ និង អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវសហការអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

សារាចរអន្តរក្រសួងស្ដីពីការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍គ្រប់ប្រភេទ លេខ០០១សរ-មផ-បទ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ត្រូវទុកជានិរាករណ៍។

រាជធានីភ្នំពេញ,ថ្ងៃទី២៨ខែកុម្ភៈឆ្នាំ២០១២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**សូ-ឃុន**

<u>ចម្លងជូន</u>:
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អភិបាលរាជធានីភ្នំពេញ- ខេត្ត« ដើម្បីជូនជ្រាបនិងសហការអនុវត្ត »
- អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានទូរគមនាគមន៍នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់« ដើម្បីអនុវត្ត »
- ឯកសារកាលប្បវត្តិ